# សេចក្តីប្រកាសព័ត៌មាន

**កំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជានឹងត្រូវពិនិត្យដោយយន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់**

**ទីក្រុងហ្សឺណែវ (២៥ មករា ២០១៩)** - កំណត់ត្រាសិទ្ធិមនុស្សរបស់កម្ពុជានឹងត្រូវពិនិត្យដោយក្រុមការងារពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ជាលើកទីបី នៅថ្ងៃពុធ ទី៣០ ខែមករា ឆ្នាំ២០១៩ នៅក្នុងកិច្ចប្រជុំមួយ ដែលនឹងចាក់ផ្សាយផ្ទាល់តាមប្រព័ន្ធវេបខាស់។

កម្ពុជាគឺជារដ្ឋមួយក្នុងចំណោមរដ្ឋចំនួន១៤ ត្រូវបានពិនិត្យដោយក្រុមការងារ UPR របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសម័យប្រជុំមួយដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ។ ការពិនិត្យរបាយការណ៍ UPR លើកទី១ និងលើកទី២ របស់កម្ពុជា ត្រូវបានធ្វើឡើងជាបន្តបន្ទាប់គ្នា ក្នុងខែធ្នូ ឆ្នាំ២០០៩ និងខែមករា ឆ្នាំ២០១៤។

ការពិនិត្យនេះ ផ្អែកលើឯកសារ៖ ១) របាយការណ៍ជាតិ - ព័ត៌មានដែលផ្តល់ឱ្យដោយរដ្ឋស្ថិតក្រោមការពិនិត្យ ២) ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញ និងក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យ ដែលគេស្គាល់ថាជានីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងអង្គភាពដទៃទៀតរបស់អង្គការសហប្រជាជាតិ ៣) ព័ត៌មានដែលផ្តល់ដោយភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងស្ថាប័នជាតិសិទ្ធិមនុស្ស អង្គការតំបន់ និងក្រុមសង្គមស៊ីវិល។

**របាយការណ៍**ទាំងបីនេះ ប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិនិត្យសំរាប់កម្ពុជានៅថ្ងៃទី៣០ ខែមករា ដែលអាចរកបាននៅទីនេះ។

**ទីកន្លែង៖** បន្ទប់លេខ២០ Palais des Nations ទីក្រុងហ្សឺណែវ

**ម៉ោងនិងកាលបរិច្ឆេទ៖** ៨:៣០ នាទី យប់ ដល់ម៉ោង ១២:00 ថ្ងៃពុធ ទី៣០ ខែមករា (ម៉ោងនៅរាជធានីភ្នំពេញ)

UPR គឺជាដំណើរការតែមួយគត់ដែលពាក់ព័ន្ធនឹងការពិនិត្យតាមកាលកំណត់នូវកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកអង្គការសហប្រជាជាតិទាំង១៩៣រដ្ឋ។ ចាប់តាំងពីកិច្ចប្រជុំលើកទី១ របស់ខ្លួន ត្រូវបានប្រារព្ធឡើង នៅខែមេសា ឆ្នាំ២០០៨ មក រដ្ឋទាំង១៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានពិនិត្យពីរដងរួចមកហើយ នៅក្នុងជុំទី១ និងជុំទីពីរនៃUPR ។ នៅក្នុងអំឡុងពេលជុំទី៣ នៃ UPR នេះ រដ្ឋទាំងឡាយ ត្រូវបានគេរំពឹងម្តងទៀតថា នឹងបង្ហាញប្រាប់ពីវិធានការផ្សេងៗ ដែលរដ្ឋខ្លួនបានចាត់ឡើង ដើម្បីអនុវត្តអនុសាសន៍ទាំងឡាយដែលបានលើកឡើង នៅក្នុងអំឡុងពេលនៃការពិនិត្យលើកមុន ដែលរដ្ឋខ្លួនបានប្តេជ្ញាអនុវត្តតាម ហើយក៏ដូចជា ដើម្បីគូសបញ្ជាក់ពីវឌ្ឍនភាពសិទ្ធិមនុស្សថ្មីៗ នៅក្នុងប្រទេសរបស់ខ្លួន។

ឯកឧត្តម កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នឹងដឹកនាំគណៈប្រតិភូកម្ពុជា។

តំណាងប្រទេសចំនួនបី ដែលធ្វើជាអ្នករាយការណ៍ ("ត្រយកា") សម្រាប់ការត្រួតពិនិត្យរបាយការណ៍របស់កម្ពុជា គឺប្រទេសប៉ាគីស្ថាន សេណេហ្គាល់ និងចក្រភពអង់គ្លេស។

**វិបខាស់**នៃសម័យប្រជុំនេះ នឹងមាននៅលើគេហទំព័រ http://webtv.un.org

បញ្ជីឈ្មោះវាគ្មិន និងសេចក្តីថ្លែងការណ៍ដែលមានទាំងអស់ ដែលត្រូវថ្លែងនៅក្នុងអំឡុងពេលពិនិត្យរបាយការណ៍របស់កម្ពុជានឹងត្រូវដាក់បង្ហោះនៅលើ UPR Extranet តាមរយៈតំណភ្ជាប់ខាងក្រោមនេះ [username: **hrc extranet** (មានដក); password: **1session**].

ក្រុមការងារ UPR **គ្រោងនឹងអនុម័តអនុសាសន៍នានា** ដែលបានធ្វើឡើងសម្រាប់កម្ពុជានៅម៉ោង ១៧.៣០ ថ្ងៃទី១ ខែកុម្ភៈ។ រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យ-កម្ពុជា អាចនឹងបង្ហាញពីជំហររបស់ខ្លួនលើអនុសាសន៍ដែលត្រូវបានធ្វើចំពោះខ្លួន នៅក្នុងអំឡុងការពិនិត្យឡើងវិញនេះ។ អនុសាសន៍ទាំងនេះ នឹងត្រូវធ្វើការចែករំលែកជាមួយប្រព័ន្ធផ្សព្វផ្សាយនៅថ្ងៃនេះជាមុន។

**ចប់**

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទង ៖ **លោក រ៉ូឡង់ដូ ហ្គោមេ** តាមរយៈទូរស័ព្ទលេខ +៤១ (0) ២២ ៩១៧ ៩៧១១/ rgomez@ohchr.org ឬ **សេដ្រិក សេផេ** តាមរយៈទូរស័ព្ទលេខ +៤១ (0) ២២ ៩១៧ ៩៨៤៥/ csapey@ohchr.org*

*ដើម្បីស្វែងយល់បន្ថែមអំពីយន្តការពិនិត្យរបាយការណ៍តាមកាលកំណត់ សូមចូលទៅកាន់៖ www.ohchr.org/hrc/upr*

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប សូមស្វែងយល់ពីយើងតាមរយៈបណ្តាញសង្គម៖** Facebook Twitter YouTube Instagram